## លទ្ធផលនៃកិច្ចពិភាក្សាពីបណ្តាញ CSOs

## ការពិភាក្សានៅលើជម្រើសនៃការអនុវត្តរេដបូកនៅកម្ពុជា

**ជម្រើស៣ផ្សេងគ្នាពាក់ព័ន្ធនឹងរេដបូក៖**

ជម្រើសទី១) រេដ+ផ្អែកតាមគម្រោង (Project based REDD+)

ជម្រើសទី២) រេដ+ថ្នាក់ក្រោមជាតិ (Sub-national REDD+)

ជម្រើសទី៣) រេដ+ថ្នាក់ជាតិ (National REDD+)

**អនុសាសន៍៖**

- សុំពិគ្រោះយោបល់ឲ្យបានទូលំទូលាយ មុននឹងធ្វើការសម្រេចចិត្ត

**ការជ្រើសរើសជម្រើរេដបូកថ្នាក់ជាតិ (National REDD+)៖**

1. រដ្ឋាភិបាលជាអ្នកទទួលខុសត្រូវលើការកាប់បំផ្លាញព្រៃឈើ និង ការបំភាយឧស្ម័ន។
2. អាចដោះស្រាយនូវកត្តាជម្រុញឲ្យមានការកាប់បំផ្លាញព្រៃឈើក្នុងប្រទេសទាំងមូល។ ប៉ុន្តែបើសិនជាអនុវត្តន៍រេដបូក ផ្អែកតាមគម្រោង គឺអាចដោះស្រាយបានតែកត្តាជម្រុញឲ្យមានការកាប់បំផ្លាញព្រៃឈើតែក្នុងកម្រិតគម្រោងទេ។
3. កាត់បន្ថយឈ្មួញកណ្តាលក្នុងការលក់កាបូន។
4. ការផ្ទៀងផ្ទាត់ត្រូវធ្វើឡើងដោយ UNFCCC។
5. ហិរញ្ញវត្ថុរេដ+នៅថ្នាក់ជាតិ អាចរួមវិភាគទានដល់សេចក្តីត្រូវការកម្រិតគោលនយោបាយ ដើម្បីសម្រេចលទ្ធផលនានា
6. អ្នកផ្តល់ជំនួយ និងមូលនិធិអាកាសធាតុបៃតង (Green Climate Fund) មានបំណងគាំទ្រយ៉ាងខ្លាំង ដល់ប្រទេសមួយចំនួន ឲ្យប្តូរមកអនុវត្តន៍តាមវិធានទាំងស្រុង ដែលបានព្រមព្រៀងដោយ UNFCCC។

**ការជ្រើសរើសជម្រើសរេដបូកថ្នាក់ក្រោមជាតិ៖**

១. អនុវត្តន៍គម្រោងផ្ទាល់

២. ជម្រុញវិមជ្ឈការ

៣. គាត់យល់ច្បាស់ពីស្ថានភាព/បញ្ហានៅក្នុងសហគមន៍

៤. ជំរុញអោយអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិយល់ដឹងពីរេដបូក

៥. បញ្ជ្រាបការអនុវត្តរេដក្នុងផែនការអភិវឌ្ឍន៍ឃុំ/ស្រុក/ខេត្ត

៦. សង្គមស៊ីវិលអាចធ្វើការសហការណ៍ជាមួយសហគមន៍យ៉ាងជិតស្និត
៧. ការពិគ្រោះយោបល់ និងទទួលយោបល់គ្រលប់លឿន និងដោះស្រាយទាន់សភាពការណ៍
៨. មានឱកាសក្នុងការសម្រេចចិត្តពីថ្នាក់សហគមន៍បានច្រើន
៩. ការប្រើប្រាស់ថវិកាមានប្រសិទ្ធភាព និងប្រសិទ្ធផលជាង

**អនុសាសន៍រួមៈ**

១. ត្រូវអោយនិយមន័យព្រៃឈើនៅក្នុងរេដបូក និងការអនុវត្តរេដបូក តែទៅលើព្រៃធម្មជាតិ និងព្រៃស្តារឡើងវិញ។

២. ត្រូវបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងសម្បទាននានា ដែលមានការប៉ះពាល់ដល់ព្រៃធម្មជាតិ និងជីវៈចម្រុះ ។

៣. ត្រូវមានយន្តការច្បាស់លាស់ និងបន្ទាន់ ក្នុងការទប់ស្កាត់ការបាត់បង់ព្រៃធម្មជាតិ ដែលបច្ចុប្បន្នការបាត់បង់ព្រៃធម្មជាតិកាន់តែកើនឡើង ។[1]

៤.ត្រូវមានយន្តការក្នុងការផ្លាស់ប្តូរការអនុវត្តរេដបូក ផ្អែកតាមគម្រោងទៅរេដបូកថ្នាក់ជាតិ រឺថ្នាក់ក្រោមជាតិ។

៥. ត្រូវគាំទ្រគម្រោងសាកល្បងរេដបូក សម្រាប់ជាបទពិសោធន៍ និងជាមេរៀន ក្នុងការអនុវត្តរេដបូកថ្នាក់ជាតិ។

៦. យន្តការការអនុវត្តរេដបូកថ្នាក់ជាតិ ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងត្រូវឲ្យអង្គការសង្គមស៊ីវិលចូលរួមតាមដានការអនុវត្តកម្មវិធីរេដបូក
គ្រប់ដំណាក់កាល និងពេញលេញ(ទៅតាមជំនាញ?)។

៨. ត្រូវផ្តល់ចំណេះដឹងអំពីរេដបូកដល់ភាគីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។

៩. វិភាគទានក្នុងការអនុវត្តរេដបូក ត្រូវផ្តល់ទៅឲ្យថ្នាក់ក្រោមជាតិ និងសហគមន៍ អោយបានច្រើនជាង នៅថ្នាក់ជាតិ ។

១០. បញ្ជ្រាបការអនុវត្តរេដបូកក្នុងផែនការអភិវឌ្ឍន៍ឃុំ/ស្រុក/ខេត្ត។

១១. ការទទួលផលពីការអនុវត្តកម្មវិធីរេដបូក ត្រូវតែផ្តល់ទៅឲ្យប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

១២. ព័ត៌មានក្នុងការអនុវត្តកម្មវិធីរេដបូក ត្រូវតែចែករំលែកទៅភាគីពាក់ព័ន្ធជាសាធារណៈ រួមទាំងព័ត៌មានថវិកា។

១៣. កម្មវិធីរេដបូកត្រូវតែមានតម្លាភាព។

១៤. ត្រូវមានយន្តការតាមដាន និងលំហូរព័ត៌មានច្បាស់លាស់ រួមទាំងលំហូរថវិកា។

---

[1] ព្រៃឈើក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៣ មាន៧២.១១ ភាគរយ នៃផ្ទៃប្រទេស ដល់ ២០១៣ នៅសល់តែ ៤៦.៣៣ភាគរយ http://www.opendevelopmentcambodia.net/briefings/forest-cover/